
ការពិសោធន៍ការបកគ្រាប់
ស្រូវយកទៅសាបហើយ
ស្ងួត
កសិករ សាម ហ៊ួត ភូមិ កន្ទួងរ៉ុង ឃុំ រុងរឿង
ស្រុក ស្ទោង ខេត្ត កំពង់ធំ

# I.ប្រវត្តិ

នាងខ្ញុំឈ្មោះ ស៊ាម ហួត រស់នៅភូមិ កន្ទុងរ៉ុង ឃុំ រុងរឿង ស្រុក ស្ទោង ខេត្តកំពង់ធំ  សហការជាមួយអង្គការសេដាក ចាប់តាំងពីឆ្នាំ ២០០៧ ។

យកពូជស្រូវដែលបានបកគ្រាប់ពិសោធន៍ការពីឆ្នាំ២០១៣ មកធ្វើការបកគ្រាប់សំរាប់ពិសោធន៍នៅក្នុងឆ្នាំ២០១៤ ។

តាមរយៈការផ្សព្វផ្សាយរបស់អង្គការសេដាក និង បទពិសោធន៍បានធ្វើការពីឆ្នាំ២០១៣។

# II.បច្ចេកទេសដែលបានអនុវត្ត

1. ការជ្រើសរើសពូជ

- ប្រភេទពូជស្រូវផ្ការំដួល
- ដំបូងគាត់បានយកគ្រាប់ស្រូវចំនួន៧០០គ្រាប់បក
- គ្រាប់ស្រូវបានបកហើយគាត់បានធ្វើការជ្រើសរើសយកគ្រាប់ដែលល្អបានចំនួន៥០០គ្រាប់ សំរាប់យកទៅសាប



# 2. ការសាបសំណាប

ការសាបសំណាប គឺយកគ្រាប់អង្កទៅសាបនៅក្នុងឡាំងស្នោចំនួន៣ ដែលនៅក្នុងឡាំងស្នោនោះមានដាក់ដី ដូចខាងក្រោម ៖

- ដីមោកព្រៃ
- ធ្យូងអង្កាម
- ដីកំប៉ុស្ដិ៍

# 3. ការរៀបចំដីសម្រាប់ស្ទូង

- នាងខ្ញុំបានភ្ជួររាស់ដីចំនួន ៣ ដង គឺ៖
- ភ្ជួររាស់លើកទី ១ រួចព្រោះសណ្តែកបាយ
- ភ្ជួរលើកទី ០២ លប់ដើមសណ្តែកដើម្បីបានជីស្រស់
- ពេលសណ្តែករលួយអស់ ទើបភ្ជួរមកវិញជាលើកទី ០៣ ដោយបន្ថែមជីកំប៉ុស្ត និងផ្សេងអង្កាម សម្រាប់ទ្រាប់បាត ហើយរាស់ពង្រាប រួចស្ទូងតែម្តង ។

# ៤. ការស្ទូង



- ក្នុងចំណោមសំណាប៥០០ដើម គឺគាត់បានធ្វើការជ្រើសរើសបានចំនួន ៤៨០ដើម សំរាប់ស្ទូង
- អាយុសំណាប១៤ថ្ងៃ
- ដកថ្នមៗឲ្យមានជាប់ដីខ្លះៗដាក់ចានដែក
- ដកភ្លាមស្ទូងភ្លាម យកតែសំណាបថ្លោសៗដែលមានសុខភាពល្អ
- ស្ទូងជាជួរ រាក់ៗ ចន្លោះគុម្ព ២,តឹក និងស្ទូង ១ ដើម ក្នុង១គុម្ព

# 4. ការតាមដាន និងថែទាំ



- បោចស្មៅលើកទី១ ក្រោយពេលស្ទូងចំនួន ១៥ ថ្ងៃ
- បោចស្មៅលើកទី ២ នៅពេលស្រូវអាយុបាន ១ ខែ
- ស្រូវអាយុបាន ២ខែ ដាក់ជីកំប៉ុស្ត៍កាកឡ
- រក្សាទឹកទុកតិចៗក្នុងស្រែ ដើម្បីឲ្យ ជំរុញដល់ការបែកគុម្ពរបស់ស្រូវ

# 5. ការប្រមូលផល



- សង្កេតឃើញពណ៌ស្លាបសេក និងគ្រាប់គល់កួរដាក់ម្សៅរឹង ( ទុំប្រហែល ៨០ ទៅ ៨៥ ភាគរយ )
- នៅលើផ្ទៃដីចំនួន២០ម៉ែត្រការ៉េ គាត់ទទួលបានស្រូវចំនួន
- ១១.៥គីឡូ ( ស្រូវស្ងួត ) ។

# III.ចំណាប់អារម្មណ៍

ក្រោយពីបានធ្វើការពិសោធន៍មក  ការបកគ្រាប់ស្រូវយកស្ទូងពិតជាផ្តល់ទិន្នផលច្រើនជាង ការស្ទូងធម្មតា ។ ម៉្យាងទៀតគាត់គិតថាវាជាបទពិសោធន៍ថ្មីមួយទៀតសំរាប់គាត់ យកទៅអនុវត្តន៍នៅឆ្នាំក្រោយ និងធ្វើការផ្សព្វផ្សាយដល់កសិករផ្សេងទៀតអោយអនុវត្តន៍តាម ។

# សូមអរគុណ

